ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កំណត់ហេតុកិច្ចប្រជុំ
# លើខ្លឹមសារដែលត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំ២០១៦
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# គិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦
# សាលប្រជុំក្រសួងមហាផ្ទៃ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែវិច្ឆិកា ថ្ងៃទីដប់មួយ វេលាម៉ោងប្រាំបី និងសាមសិបនាទី នៅសាលប្រជុំក្រសួងមហាផ្ទៃ មានបើកកិច្ចប្រជុំពិភាក្សាលើខ្លឹមសារ ដែលត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំ២០១៦ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ អគ្គលេខាធិការ អគ្គលេខាធិការរង គ.ជ.ប.ជ និង ឯកឧត្តម លោកជំទាវ ជាអភិបាលរងទទួលបន្ទុកលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី/ខេត្ត (គ.រ.ប.ជ/គ.ខ.ប.ជ) និង លោក លោកស្រី ប្រធាន អនុប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាល រាជធានី/ខេត្ត។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ុន វ៉ូ** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានមតិស្វាគមន៍ បើកកិច្ចប្រជុំ និងអានរបាយការណ៍លទ្ធផលការងារសង្ខេប ១០ខែ ឆ្នាំ២០១៦ ទាក់ទងនឹងអំពើជួញដូរមនុស្ស ដោយលើកយកចំណុចសំខាន់ៗមកនិយាយដើម្បីឲ្យសមាជិក នៃអង្គប្រជុំងាយស្រួលធ្វើការកែសម្រួលលើខ្លឹមសារ និងតួលេខ ដែលលេខាធិការដ្ឋាន រាជធានី/ខេត្ត បានផ្ញើមកមុន។

បន្ទាប់មក **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍ស្វាគមន៍យ៉ាងកក់ក្តៅ ដល់បណ្តាសមាជិកនៅក្នុងអង្គប្រជុំទាំងមូល លោកជំទាវបានមានប្រសាសន៍ទាក់ទងទៅនឹងការអនុវត្តការងារប្រចាំថ្ងៃរបស់ក្រុមការងារ និងលេខាធិការដ្ឋាន រាជធានី/ខេត្ត ត្រូវអនុវត្តតាមផែនការយុទ្ធសាសន៍ទាំងបួនចំណុច និងត្រូវរៀបចំផែនការរបស់ខ្លួនឲ្យបានច្បាស់លាស់ ដើម្បីពង្រឹងសកម្មភាពការងារ និងទទួលបានជោគជ័យ។ លោកជំទាវ មានប្រសាសន៍បន្តលើការផ្សព្វផ្សាយអប់រំ ដល់ប្រជាពលរដ្ឋ តាមមូលដ្ឋានអំពីការជួញដូរមនុស្ស ត្រូវធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយជាពិសេសអំពីផលវិបាក នៃ

ការធ្វើចំណាកស្រុកទៅក្រៅប្រទេស សព្វថ្ងៃប្រជាពលរដ្ឋជាកសិករនៅតាមជនបទមានចំនួន ប្រហែល៩០ភាគរយប៉ុណ្ណោះ ដោយសារប្រជាពលរដ្ឋទាំងនោះត្រូវការថវិការដើម្បីដោះស្រាយជីវភាព ព្រោះទិន្នផលកសិកម្មដែលគាត់ទទួលបានហើយ តែលក់ពុំបានថ្លៃ។ ប្រទេសគោលដៅ(ថៃ) គេកំពុងប្តូរគោលនយោបាយ និងបានពន្យាពេលប័ណ្ណស៊ីជម្ពូរហូតដល់រយៈពេលដប់ឆ្នាំ ហើយបានសន្យាថានឹងតម្លើងប្រាក់ខែឲ្យពលករថែមទៀតផង តើយើងអាចយកបានដែរឬទេ? សព្វថ្ងៃយើងកំពុងតែដើរពីក្រោយថៃដោយចាញ់ប្រៀប។ ការគ្រប់គ្រងពលករ គឺយើងមិនទាន់គ្រប់គ្រងបានច្បាស់លាស់ទេ។ **លោកជំទាវ** មានប្រសាសន៍បន្ថែមថា ការងារបង្ការទប់ស្កាត់ មិនមែនមានតែការអប់រំផ្សព្វផ្សាយនោះទេ វាមានច្រើនបែបច្រើនយ៉ាង យើងអាចធ្វើការតាមជំនាញរបស់មន្ទីរ ស្ថាប័ននីមួយៗ។ ចំពោះលេខាធិការដ្ឋាន រាជធានី/ខេត្ត ត្រូវធ្វើការសហការជាមួយមន្ទីរ ស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត ជាពិសេសការផ្តល់សេវាសមស្របជូនជនរងគ្រោះពេលពួកគាត់ត្រឡប់មកវិញ។ ត្រូវអនុវត្តការងារ ឲ្យមានភាពស៊ីសង្វាក់គ្នា បើមិនដូច្នេះទេ គឺមិនអាចទទួលបានជោគជ័យឡើយ។

បន្ទាប់មកទៀត **លោកជំទាវ ជូ ប៊ុនអេង** បានអនុញ្ញាតិឲ្យតំណាងក្រសួង ស្ថាប័ន និងបណ្តាលេខាធិការដ្ឋាន រាជធានី/ខេត្ត ឡើងមានមតិកែសម្រួលលើខ្លឹមសារ និងតួលេខរបាយការណ៍ថ្នាក់ជាតិឆ្នាំ២០១៦ ដែលបានអនុវត្តកន្លងមក ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហើយមានតំណាងលេខាធិការដ្ឋានខេត្តមួយចំនួនបានឡើងមានមតិកែសម្រួលនូវចំនួនតួលេខ ដែលក្រុមការងារបច្ចេកទេសថ្នាក់ជាតិមានការខ្វះចន្លោះ និងមានការបញ្ចេញមតិយោបល់ជាសំណូមពរ ក៏ដូចជាផ្តល់នូវបទពិសោធន៍ការងារខ្លះៗដល់បណ្តាខេត្តផ្សេងៗដើម្បីយកទៅអនុវត្តឲ្យទទួលបានជោគជ័យ។ បន្ទាប់មក **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** បានមានប្រសាសន៍ទាក់ទងទៅនឹងការអនុវត្តន៍ការងារមួយចំនួន និងបានផ្តល់អនុសាសន៍ទាក់ទងនឹងការគ្រប់គ្រងថវិការបស់ថ្នាក់ រាជធានី/ខេត្ត ទៅលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ គណៈកម្មាធិការរាជធានី/ខេត្ត(គ.រ.ប.ជ/គ.ខ.ប.ជ) គឺមានកញ្ចប់ថវិការបស់ខ្លួន ហើយការស្នើសុំអ្វីមួយ គឺធ្វើការទៅតាមខ្សែរយៈរបស់ខ្លួន ចំពោះខេត្តខ្លះមានថវិការតិចឬច្រើន គឺអាស្រ័យទៅលើសកម្មភាពការងាររបស់ខ្លួន ច្រើន ឬតិចតែប៉ុណ្ណោះ។

ចុងបញ្ចប់ នៃកិច្ចប្រជុំ លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ជូនពរដល់សមាជិកក្នុងអង្គប្រជុំទាំងមូល ព្រមទាំងក្រុមការងារ សូមសម្រេចបានជោគជ័យគ្រប់ភារកិច្ចការងារ និងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កំបីឃ្លៀងឃ្លាតឡើយ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ដប់មួយ និងសែសិបប្រាំនាទី ថ្ងៃខែឆ្នាំដដែល។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦

**អ្នកធ្វើកំណត់ហេតុ**

គោរពជូន

**លោកជំទាវអនុប្រធានអចិន្ត្រៃយ៍**

**គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ[illegible] ឆ្នាំ២០១៦

ប្រធានលេខាធិការដ្ឋាន

ឧត្តមសេនីយ៍ត្រី គង់ - ឫទ្ធី

ជូ-ប៊ុនអេង

07/12/2016

**សមាសភាពអញ្ជើញចូលរួមកិច្ចប្រជុំ**
**លើខ្លឹមសារដែលត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំ២០១៦**
**ស្តីពី**
**ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**
**គិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦**
**សាលប្រជុំក្រសួងមហាផ្ទៃ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦**

| | | |
|---|---|---|
| ១.លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ |
| ២.ឯ.ឧ ឧ.ឯក | ថោង សំអាត | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៣.ឯ.ឧ ឧ.ឯក | ស៊ុន រ៉ូ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៤.ឯ.ឧ ឧ.ឯក | ខៀវ ចាន់ប៉ា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៥.ល.ជំ ឧ.ឯក | ប៉ុណ្ណ សំខាន់ | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៦.លោក ឧ.ត្រី | កែប សារឿន | ប្រធាននាយកដ្ឋាន គ.ជ.ប.ជ |
| ៧.លោក ឧ.ត្រី | គង់ ពុទ្ធី | ប្រធានលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៨.លោក ឧ.ត្រី | លី តុងហ៊ុយ | ប្រធាននាយកដ្ឋាន គ.ជ.ប.ជ |
| ៩.លោកជំទាវ | ឃួន យុនឌី | អភិបាលរងខេត្តកំពង់ធំ |
| ១០.លោកជំទាវ | ប៊ឹង ហេង | អភិបាលខេត្តព្រះវិហារ |
| ១១.លោកជំទាវ | ប៉ុក ណាឌី | អភិបាលរងខេត្តបន្ទាយមានជ័យ |
| ១២.លោកជំទាវ | សួស សារ៉ាម | អភិបាលរងខេត្តកណ្តាល |
| ១៣.លោកជំទាវ | នូ សុវណ្ណនី | អភិបាលរងខេត្តតាកែវ |
| ១៤.លោកជំទាវ | គង់ ស៊ីផា | អភិបាលរងខេត្តស្ទឹងត្រែង |
| ១៥.លោកជំទាវ | យូ សុគន្ធ | អភិបាលរងខេត្តកំពត |
| ១៦.លោកជំទាវ | លៀង ស្រីម៉ុល | អភិបាលរងខេត្តព្រៃវែង |
| ១៧.ឯកឧត្តម | ផៃធូន ផ្លាមកេសន | អភិបាលរងខេត្តកោះកុង |
| ១៨.លោកជំទាវ | ប៉ាល់ យឿន | អភិបាលរងខេត្តកំពង់ឆ្នាំង |
| ១៩.លោកជំទាវ | ឯក សុវណ្ណការៈ | អភិបាលរងខេត្តឧត្តមានជ័យ |
| ២០.លោកជំទាវ | ឡេង សិលា | អភិបាលរងខេត្តត្បូងឃ្មុំ |
| ២១.លោកជំទាវ | ប៊ិន សុភី | អភិបាលរងខេត្តក្រចេះ |
| ២២.លោកជំទាវ | ពៅ សុភាព | អភិបាលរងខេត្តស្វាយរៀង |
| ២៣.លោកជំទាវ | ញ៉ឹក សុគន្ធ | អភិបាលរងខេត្តបាត់ដំបង |
| ២៤.លោកជំទាវ | ជា លាក | អភិបាលរងខេត្តប៉ៃលិន |

| | | |
|---|---|---|
| ៥៥.លោក | អ៊ុំ ជារ៉ែន | មន្ត្រី គ.ជ.ប.ជ |
| ៥៦.លោក | អ៊ុច ចាន់ជា | នាយរងការិយាល័យ គ.ជ.ប.ជ |
| ៥៧.លោក | អ៊ុន សុខជា | មន្ត្រី គ.ជ.ប.ជ |
| ៥៨.លោក | ឱក សត្យា | មន្ត្រី គ.ជ.ប.ជ |
| ៥៩.លោក | សៅ ស៊ីនួន | មន្ត្រី គ.ជ.ប.ជ |
| ៦០.លោក | ម៉ាច បូនិច | PM ( Cambodia Acts ) |
| ៦១. | ជេត ជុំ | នាយករងរដ្ឋបាល សាលាខេត្តកំពង់ស្ពឺ |
| ៦២. | វង សុផល | ប្រធានលេខាធិការដ្ឋាន ខេត្តកោះកុង |
| ៦៣. | ជិន អោវ | នាយការិយាល័យ ខេត្តកំពត |
| ៦៤. | ជុំ ចាន់ធឿន | អនុប្រធានការិយាល័យ ខេត្តកែប |
| ៦៥. | អ៊ុក ស៊ីវន្ថា | នាយិការរងទីចាត់ការ ខេត្តក្រចេះ |
| ៦៦. | ហុក ផល្លី | ប្រធានការិយាល័យទំនាក់ទំនង ខេត្តកំពង់ធំ |
| ៦៧. | នូ សំណាត | នាយរងរដ្ឋបាល សាលាខេត្តកែប |
| ៦៨. | វេន ច័ន្ទសុភា | មន្ត្រីលេខាធិការដ្ឋាន ខេត្តកណ្តាល |
| ៦៩. | នួន ណុយ | មន្ត្រីលេខាធិការដ្ឋាន ខេត្តកំពង់ចាម |
| ៧០. | ចៀម សុភ៉ាម | ក្រុមការងារ គ.ខ.ប.ជ ខេត្តសៀមរាប |
| ៧១. | ហួយ សុវត្ថិវាសនា | សមាជិកលេខាធិការដ្ឋាន សាលាខេត្តកំពង់ឆ្នាំង |
| ៧២. | ថន វ៉ាន់ដាប៉ា | មន្ត្រីសាលាខេត្តកំពត |

**សរុបៈ ចំនួន ៧២ រូប**

| | | |
|---|---|---|
| ២៥.លោកជំទាវ | យូ សុភា | អភិបាលរងខេត្តសៀមរាប |
| ២៦.លោកជំទាវ | អាយស៊ី សុគន្ធារី | អភិបាលរងខេត្តមណ្ឌលគិរី |
| ២៧.លោកជំទាវ | ហៀក ហ៊ីមុល្លី | អភិបាលរងខេត្តព្រះសីហនុ |
| ២៨.លោកជំទាវ | កែវ សារឿន | អភិបាលរងខេត្តរតនៈគិរី |
| ២៩.លោកជំទាវ | ជុក សុផានី | អភិបាលរងខេត្តពោធិ៍សាត់ |
| ៣០. | សាន់ សារឿន | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តប៉ៃលិន |
| ៣១. | សោម សុខា | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តបាត់ដំបង |
| ៣២. | ប៉ែន កញ្ញា | ស្នងការរង នៃស្នងការដ្ឋាននគរបាល ព្រះសីហនុ |
| ៣៣. | នៅ រតនា | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តក្រចេះ |
| ៣៤. | ប៊ី សារីន | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តស្វាយរៀង |
| ៣៥. | កែវ នី | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តកោះកុង |
| ៣៦. | ព្រាប សារី | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តព្រៃវែង |
| ៣៧. | សុខ សំ | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តសៀមរាប |
| ៣៨. | អ៊ិត សុខុម | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តកំពុងធំ |
| ៣៩. | ផេង តារា | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តឧត្តមានជ័យ |
| ៤០. | ថន សុពៅ | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តត្បូងឃ្មុំ |
| ៤១. | អៀម វណ្ណី | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តកំពង់ចាម |
| ៤២. | ណឹម វណ្ណារី | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តកណ្តាល |
| ៤៣. | ងិន សុគន្ធា | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តកំពង់ស្ពឺ |
| ៤៤. | ចាប យ៉ម | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តពោធិ៍សាត់ |
| ៤៥. | ស្រី ថាន់ | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តស្ទឹងត្រែង |
| ៤៦. | កែវ ដារី | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តរតនៈគិរី |
| ៤៧. | គុច គ្គានី | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តតាកែវ |
| ៤៨. | នៃ សំណាង | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តព្រះវិហារ |
| ៤៩. | ចឹក ផល្លា | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តកែប |
| ៥០. | ហួន គឹមហេង | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តមណ្ឌលគិរី |
| ៥១. | មាស សុម៉ាលី | ស្នងការរង នៃស្នងការដ្ឋាននគរបាល ខេត្តកំពង់ឆ្នាំង |
| ៥២.លោក វ.ឯក | ថោង វុទ្ធី | អនុប្រធានលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៥៣.លោក | តែ សុថារ៉េត | អនុប្រធាននាយកដ្ឋាន គ.ជ.ប.ជ |
| ៥៤.លោក | អ៊ុំ កាមិន្ទ | ប្រធានការិយាល័យផ្សព្វផ្សាយ អប់រំ គ.ជ.ប.ជ |